# ប្រធានសិទ្ធិមនុស្សអ.ស.ប លោក ហ្សេដ បង្ហាញរបាយការណ៍ប្រចាំឆ្នាំរបស់លោក ទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្ស

ពេលបង្ហាញរបាយការណ៍ប្រចាំឆ្នាំរបស់លោកជូនទៅក្រុមប្រឹក្សាសិទ្ធិមនុស្ស លោកប្រធានសិទ្ធិមនុស្ស អ.ស.ប លោក ហ្សេដ បានមានប្រសាសន៍ថា លោកបានដឹងពីការកើនឡើងដែលមិនធ្លាប់មាននៃការគំរាមកំហែងដល់លំហប្រជាធិបតេយ្យនៅទូទាំងពិភពលោក។

ការចាប់ខ្លួន ការយាយី និងការកាត់ទោសតួអង្គសង្គមស៊ីវិល ដែលបានកត់សម្គាល់ក្នុងឆ្នាំ ២០១៥ គឺផ្ទុយទៅនឹងការផ្តល់សច្ចាប័នលើសន្ធិសញ្ញា និងកិច្ចព្រមព្រៀងសិទ្ធិមនុស្ស អ.ស.ប ដែលគួរតែតំណាងឲ្យការប្តេជ្ញាចិត្តរបស់រដ្ឋនានាក្នុងការការពារសិទ្ធិមនុស្ស។ បើគ្មានសេរីភាពពិតប្រាកដជាក់ស្តែងនៅនឹងកន្លែងទេ ហានិភ័យនៃការផ្តល់សច្ចាប័នទាំងនោះ គឺងាយនឹងក្លាយជាអ្វីដែលថា "សិទ្ធិមនុស្សដាក់តាំងបង្ហាញគ្រាន់តែឲ្យល្អមើលនោះឡើយ" លោក ហ្សេដ បានមានប្រសាសន៍ដូច្នេះ ដោយសង្កត់ធ្ងន់ថា៖ "កាតព្វកិច្ចសិទ្ធិមនុស្សមិនគួរជាលំហាត់ "គូសប្រអប់" ដែលរចនាឡើងគ្រាន់តែដើម្បីលើកមុខមាត់របស់ប្រទេសមួយនៅលើឆាកអន្តរជាតិនោះឡើយ"។

លោកបានមានប្រសាសន៍ថា ស្ថានភាពរបស់ជនចំណាកស្រុក និងជនភៀសខ្លួន ដែលបានឈានដល់ច្រាំងសមុទ្រនៃទ្វីបអឺរ៉ុប គឺជា "សោកនាដកម្ម"។ លោកបានព្រមានសហភាពអឺរ៉ុបអំពីការរៀបចំសេចក្តីព្រាងរបស់ខ្លួនជាមួយប្រទេសតួកគី ដែលបានប្រកាសកាលពីដើមសប្តាហ៍នេះ ដែលលោកបានមានប្រសាសន៍ថា ការរៀបចំសេចក្តីព្រាងនោះអាចនាំឲ្យមាន "ការបណ្តេញទាំងក្រុមៗ និងដោយបំពាន" និងនាំឲ្យមានការរិតត្បិតនៅតាមច្រកចេញចូលព្រំដែន ដល់មនុស្សមានសញ្ជាតិជាក់លាក់ជាច្រើន ដែលផ្ទុយនឹងច្បាប់អន្តរជាតិ និងអឺរ៉ុប។

មនុស្សជាង ៤០០ នាក់ បានស្លាប់កាលពីឆ្នាំមុន ដែលពួកគេបានភៀសខ្លួនទៅអឺរ៉ុបដើម្បីគេចចេញពីជម្លោះ និងការដកហូតសិទ្ធិ ខណៈពេលដែលមានមនុស្សជាច្រើនទៀត បន្តស្លាប់នៅមជ្ឈឹមបូព៌ា លោក ហ្សេដ បានចង្អុលបង្ហាញ ដោយលើកឡើងពីស្ថានភាពនៅក្នុងប្រទេសស៊ីរី យេម៉ែន និងប្រទេសអ៊ីរ៉ាក់។

នៅប្រទេសអាហ្វ្រិកខាងជើង របាយការណ៍ថ្មីៗនេះ ដែលបានចេញដោយការិយាល័យសិទ្ធិមនុស្ស អ.ស.ប បានផ្តល់ព័ត៌មានលម្អិតអំពីការរឹតត្បិត និងការរំលោភបំពានសិទ្ធិមនុស្ស ដែលកើតឡើងដោយនិទណ្ឌភាពទាំងស្រុងនៅប្រទេសលីប៊ី និងស៊ូដង់ខាងត្បូង។

លើសពីនេះទៀត នៅភាគខាងត្បូង ប្រទេសបួគីណាហ្វាសូ និងសាធារណរដ្ឋអាហ្វ្រិកណ្តាល បានធ្វើជាគំរូសម្រាប់លទ្ធិប្រជាធិបតេយ្យនៅទ្វីបអាហ្វ្រិក ដោយមានការរៀបចំបោះឆ្នោតដោយសន្តិវិធី និងយុត្តិធម៌ ខណៈពេលដែល ប្រទេសប៊ូរុនឌី និងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ បន្តធ្វើឲ្យប៉ះពាល់ដល់ស្ថេរភាពដ៏ផុយស្រួយ ដែលហៀបនឹងដួលរលំនៅក្រោមទម្ងន់នៃការរឹតត្បិតសិទ្ធិមនុស្សទៅលើពលរដ្ឋរបស់ខ្លួន។

លោក ហ្សេដ បានចង្អុលបង្ហាញថា វិបត្តិមេរោគស៊្សីកា នៅអាមេរិកឡាទីនមិនត្រឹមតែជាការសង្គ្រោះបន្ទាន់សុខភាពសាធារណៈប៉ុណ្ណោះទេ ថែមទាំងជាបញ្ហាប្រឈមមួយដល់សិទ្ធិសុខភាពផ្លូវភេទ និងសុខភាពបន្តពូជរបស់ស្ត្រីនៅក្នុងតំបន់ ព្រមទាំងបញ្ហាប្រឈមដល់ការថែរទាំកុមារដែលកើតមកមានពិការភាពពាក់ព័ន្ធនឹងមេរោគស៊្សីកាផងដែរ។

លោកបានមានប្រសាសនស៍ថា៖ "ការផ្សារភ្ជាប់គ្នាយ៉ាងច្បាស់ រវាងមេរោគស៊្សីកា និងឧប្បត្តិវហេតុកើតមកក្បាលតូចដែលឃើញមានលើទារកទើបកើត បាននាំឲ្យរដ្ឋាភិបាលជាច្រើន ផ្តល់អនុសាសន៍ថា ស្ត្រីនៅក្នុងតំបន់ដែលរងផលប៉ះពាល់ ជៀសវាងពីការមានផ្ទៃពោះ"។ "ទោះជាយ៉ាងណា នៅប្រទេសជាច្រើន មានអត្រាអំពើហិង្សាផ្លូវភេទខ្ពស់ ហើយការទទួលបានសេវាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជត្រូវបានរឹតត្បិតយ៉ាងខ្លាំង ជាពិសេសជនក្រីក្រ"។

នៅឆ្នាំចាប់ផ្តើមទសវត្សរ៍អន្តរជាតិសម្រាប់មនុស្សមានដើមកំណើតអាហ្វ្រិក អាមេរិកដើមកំណើតអាហ្វ្រិក ប្រហែល ៣០០ នាក់ បានសម្លាប់ដោយក្រុមនគរបាល ហើយ ចំនួន ២.០០០ នាក់ បានសម្លាប់ដោយនគរបាលនៅប្រទេសប្រេស៊ីល ដែលជាចំនួនមិនស្មើគ្នា ជាយុវជនមានដើមកំណើតអាហ្វ្រិក។

នៅផ្នែកម្ខាងទៀតនៃពិភពលោក នៅប្រទេសនេប៉ាល់ មានការរីកចម្រើនតិចតួចក្នុងការដោះស្រាយឫសគល់នៃជម្លោះដែលនៅទីបំផុតបានបញ្ចប់ បន្ទាប់ពីកើតមានអស់រយៈពេលមួយទសវត្សរ៍។ "ការរើសអើងជនជាតិភាគតិច និងការរើសអើងវណ្ណៈដែលហាក់ដូចជាមិនអាចកែប្រែបាន វិសមភាពនៃការទទួលបានធនធានសេដ្ឋកិច្ច ភាពក្រីក្រធ្ងន់ធ្ងរ និងនិទណ្ឌភាពដែលកំពុងរាលដាល។ ប្រសិនបើ បញ្ហាដែលកំពុងឆេះយ៉ាងសន្ធោរសន្ធៅនាពេលថ្មីៗនេះ និងការរំលោភបំពានកន្លងមក មិនបានដោះស្រាយឲ្យបានត្រឹមត្រូវនោះទេ ខ្ញុំខ្លាចថា ប្រទេសនោះនឹងបន្តស្ថិតក្នុងហានិភ័យនៃកោលាហលបន្ថែមទៀត ហើយសូម្បីតែជម្លោះថ្មីក៏សឹងនឹងកើតមាន" លោកហ្សេដ បានព្រមានដូច្នេះ។ លោកក៏បានបន្ថែមទៀតថា នេះជាមេរៀនសំខាន់មួយ "សម្រាប់ប្រទេសស្រីលង្កា ដែលកំពុងធ្វើដំណើរឆ្ពោះទៅរកគណនេយ្យភាព ការផ្សះផ្សា និងសន្តិភាពយូរអង្វែង"។

ជាងនេះទៅទៀត គំនិតយោបល់ដែលរិះគន់ដល់រដ្ឋាភិបាលនៅប្រទេសចិន និងម៉ាឡេស៊ីបន្តបិទជិត។ "នៅប្រទេសម៉ាឡេស៊ី លំហប្រជាធិបតេយ្យនៅតែបន្តដាក់កម្រិត ដោយរដ្ឋាភិបាលអនុវត្ត "មធ្យោបាយបំបះបំបោរ"

និងដាក់បទចោទប្រកាន់ផ្សេងទៀតកាន់តែច្រើនដែលមិនធ្លាប់មាន ទៅលើអ្នកសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្ស គូប្រជែងនយោបាយ និងគំនិតយោបល់រិះគន់" លោក ហ្សេដ បានមានប្រសាសន៍ដូច្នេះ ដោយគូសបង្ហាញផងដែរថា លោកមានកង្វល់លើការចាប់ខ្លួនមេធាវី និងសកម្មជនផ្សេងទៀតនៅប្រទេសចិន។

លោក ហ្សេដ មានការព្រួយបារម្ភអំពីការចោទប្រកាន់ចំពោះការបន្តកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពានលើកុមារដោយកងរក្សាសន្តិភាពរបស់ អ.ស.ប នៅសាធារណរដ្ឋអាហ្វ្រិកកណ្តាល។

លោកបានសង្កត់ធ្ងន់ថា "មានតែរដ្ឋសមាជិកទេអាចធ្វើសកម្មភាពដើម្បីបញ្ចប់និទណ្ឌភាពចំពោះបទល្មើសព្រហ្មទណ្ឌបាន រាប់ទាំង ការរំលោភបំពានផ្លូវភេទ ដោយជនជាតិរបស់ខ្លួន ដែលបម្រើការឲ្យ អ.ស.ប។ មានតែរដ្ឋជាសមាជិកទេអាចធ្វើការស៊ើបអង្កេតព្រហ្មទណ្ឌ និងធ្វើការកាត់ទោសបាន"។

ជាចុងក្រោយ លោក ហ្សេដ បានលើកឡើងពីស្ថានភាពហិរញ្ញវត្ថុរបស់ការិយាល័យលោក ដែលលោកសង្ឃឹមថានឹងមានកំណែទម្រង់រចនាសម្ព័ន្ធដើម្បីឲ្យការិយាល័យមួយនេះកាន់តែខិតទៅជិតតំបន់នានា ដោយបង្កើតមណ្ឌលតំបន់ថ្មីៗជាច្រើន។ ការិយាល័យសិទ្ធិមនុស្ស អ.ស.ប ពឹងផ្អែកយ៉ាងខ្លាំងលើការបរិច្ចាគថវិកាបន្ថែមដោយរដ្ឋទាំងឡាយ។ ដើម្បីឆ្លើយតបជាវិជ្ជមានទៅនឹងសំណើសុំជំនួយដែលខ្លួនទទួល ការិយាល័យសិទ្ធិមនុស្ស អ.ស.ប នឹងត្រូវការ ២១៧ លាន ដុល្លារអាមេរិក។ តែទោះជាតម្រូវការក្នុងចំនួននេះក៏ដោយ ការព្យាករបស់ខ្លួនលើអ្វីដែលខ្លួននឹងទទួលបានជាក់ស្តែងគឺ ចំនួន ១៣០ លាន។

លោកបានមានប្រសាសន៍ថា "គម្លាតរវាងតួលេខទាំងពីរនោះ តំណាងឲ្យមនុស្សដែលយើងមិនអាចជួយបាន។ ការិយាល័យនានាតាមមូលដ្ឋាន ដែលយើងមិនអាចបើកបាន។ ការពិតគឺថា យើងមិនអាចបង្កើត ហើយយើងមិនអាចជួយ ឬតំណាងឲ្យជនរងគ្រោះបាន" ។